# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
Ministry of Industry & Handicraft
លេខ: ៦០៣ MIH / ២០១៨

# សេចក្ដីសម្រេច
## ស្ដីពី
## ការបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំ និងរបៀបរបបការងាររបស់ថ្នាក់ដឹកនាំ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៨ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៧៥ អនក្រ.បក ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- យោងតាមសំណូមពរការងារចាំបាច់

## <u>សម្រេច</u>

**ប្រការ១ ៖** បែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម សំដៅធានាការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តឱ្យមានប្រសិទ្ធភាព និងទទួលខុសត្រូវដឹកនាំតាមតាមវិស័យការងារដូចខាងក្រោម ៖

**ក- រដ្ឋមន្ត្រី ៖**

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** **ទេសរដ្ឋមន្ត្រី** និងជា **រដ្ឋមន្ត្រី** ទទួលបន្ទុកដឹកនាំរួមលើគ្រប់វិស័យការងាររបស់ក្រសួង ជាពិសេស ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដែលពាក់ព័ន្ធនឹងតួនាទី ភារកិច្ចរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្ម និងទទួលបន្ទុកដោយផ្ទាល់លើការងារ ៖

- ចាត់តាំងមន្ត្រី
- អគ្គាធិការដ្ឋាន, នាយកដ្ឋានសវនកម្មផ្ទៃក្នុង, នាយកដ្ឋានរដ្ឋបាល, នាយកដ្ឋានបុគ្គលិក, នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ, អង្គភាពរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, អង្គភាពរដ្ឋាករទឹកស្វយ័តសៀមរាប, ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃច្រកចេញចូលតែមួយ
- គណៈកម្មាធិការលទ្ធកម្ម



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

- សម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានីភ្នំពេញ មន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពត និង
- បំពេញភារកិច្ចដទៃទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ខ- រដ្ឋលេខាធិការ ៖**

១- ឯកឧត្តម **សាត សាមី** ទទួលជា **រដ្ឋលេខាធិការប្រចាំការ** និងជួយរដ្ឋមន្ត្រីលើការងារវិទ្យាស្ថានស្តង់ដារកម្ពុជា និងជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ចាម។

២- ឯកឧត្តម **គោគ សុវណ្ណរិទ្ធ**
- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម, មជ្ឈមណ្ឌលផលិតភាពជាតិ, ជួយចង្អោមការងារ **ឯកឧត្តម អ៊ិច ប៉ូរ៉ា** ពាក់ព័ន្ធនឹងនាយកដ្ឋានវាយតម្លៃទទួលស្គាល់ និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ស្ពឺ។

៣- ឯកឧត្តម **ឯក សុនចាន់**
- ជួយរដ្ឋមន្ត្រីលើការងារអគ្គនាយកដ្ឋានទឹកស្អាត, រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, ជួយចង្អោមការងារ **ឯកឧត្តម អ៊ុំ សុថា** ពាក់ព័ន្ធនឹងអង្គភាពរដ្ឋាករទឹកស្វយ័តសៀមរាប និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះសីហនុ។

៤- ឯកឧត្តម **ហេង សុខគង់**
- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន, នាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម, ជួយចង្អោមការងារ **ឯកឧត្តម អ៊ិច ប៉ូរ៉ា** ពាក់ព័ន្ធនឹងនាយកដ្ឋាននីតិកម្ម, ជួយចង្អោមការងារ **ឯកឧត្តម ទឹង ស៊ីនី** ពាក់ព័ន្ធនឹងនាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, ជួយចង្អោមការងារ **ឯកឧត្តម គោគ សុវណ្ណរិទ្ធ** ពាក់ព័ន្ធនឹងមជ្ឈមណ្ឌលផលិតភាពជាតិ, ជួយចង្អោមការងារ **ឯកឧត្តម គឹម ទូច** ពាក់ព័ន្ធនឹងនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម នាយកដ្ឋានកិច្ចការសិប្បកម្ម និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបន្ទាយមានជ័យ។

៥- លោកជំទាវ **ឡាយ ណាទីន**- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ, នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ, ជួយចង្អោមការងារ **ឯកឧត្តម ជួន វន** ពាក់ព័ន្ធនឹងនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ និង


ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តស្វាយរៀង។

៦- ឯកឧត្តម **គឹម ទូច**

- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ, ការងារនាយកដ្ឋាននាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម, នាយកដ្ឋានកិច្ចការសិប្បកម្ម, ជួយចង្អោមការងារ **ឯកឧត្តម អ៊ុំ សុថា** ពាក់ព័ន្ធនឹងនាយកដ្ឋានបុគ្គលិក, ជួយចង្អោមការងារ **ឯកឧត្តម ហេង សុខគង់** ពាក់ព័ន្ធនឹងនាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍន៍សហគ្រាសធុនតូចនិងមធ្យម និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រះវិហារ។

៧- ឯកឧត្តម **ជួន ទន**

- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម, នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ, ជួយចង្អោមការងារ **លោកជំទាវ ឡាយ ណារីន** ពាក់ព័ន្ធនឹងការងារនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ នាយកដ្ឋានីត្យានុកូលមាត្រាសាស្ត្រ និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តសៀមរាប។

៨- ឯកឧត្តម **អ៊ុំ សុថា**

- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋានបុគ្គលិក, នាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ, រដ្ឋាករទឹកស្វយ័តសៀមរាប, ជួយចង្អោមការងារ **ឯកឧត្តម មាន សុភា** ពាក់ព័ន្ធនឹងនាយកដ្ឋានរដ្ឋបាល ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃច្រកចេញចូលតែមួយ, ជួយចង្អោមការងារ **ឯកឧត្តម ឯក សុនចាន់** ពាក់ព័ន្ធនឹងអគ្គនាយកដ្ឋានទឹកស្អាត រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តបាត់ដំបង។

៩- ឯកឧត្តម **មាន សុភា**

- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋានរដ្ឋបាល, នាយកដ្ឋានកិច្ចការឧស្សាហកម្ម, ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃច្រកចេញចូលតែមួយ, ជួយចង្អោមការងារ **ឯកឧត្តម គឹម ទូច** និង**ឯកឧត្តម អ៊ុំ សុថា** ពាក់ព័ន្ធនឹងនាយកដ្ឋានគណនេយ្យនិងហិរញ្ញវត្ថុ និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តតាកែវ។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

១០- ឯកឧត្តម **នឹម ស៊ីនី**

- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, ជួយចង្អោមការងារ **ឯកឧត្តម ហេង សុខគង់** ពាក់ព័ន្ធនឹងនាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន, ជួយចង្អោមការងារ **ឯកឧត្តម មាន សុភា** ពាក់ព័ន្ធនឹងនាយកដ្ឋានកិច្ចការឧស្សាហកម្ម និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ឆ្នាំង។

១១- ឯកឧត្តម **អ៊ុច មូរ៉ា**

- ជួយរដ្ឋមន្ត្រីលើការងារនាយកដ្ឋាននីតិកម្ម, នាយកដ្ឋានវាយតម្លៃទទួលស្គាល់, ជួយចង្អោមការងារ **ឯកឧត្តម ភោគ សុវណ្ណរិទ្ធ** ពាក់ព័ន្ធនឹងនាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកណ្តាល។

**គ- អនុរដ្ឋលេខាធិការ ៖**

១- ឯកឧត្តម **កែ គី**

- ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន, នាយកដ្ឋានកិច្ចការឧស្សាហកម្ម, ជួយចង្អោមការងារ **ឯកឧត្តម ចាន់ សារ៉ែន** ពាក់ព័ន្ធនឹងនាយកដ្ឋាននីតិកម្ម និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តក្រចេះ។

២- លោកជំទាវ **ឃុន ទ៉ាវី**

- ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា, មជ្ឈមណ្ឌលផលិតភាពជាតិ និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកំពង់ធំ។

៣- ឯកឧត្តម **សយ គីរមៀ**

- ជួយថ្នាក់ដឹកនាំក្រសួងលើការងារអគ្គនាយកដ្ឋានទឹកស្អាត និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តព្រៃវែង។

៤- ឯកឧត្តម **លឹម គន់**

- ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម, នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តមណ្ឌលគិរី។



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

៥- ឯកឧត្តម **សុន សេខហួត** - ជួយថ្នាក់ដឹកនាំក្រសួងលើការងារអគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម និង

- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកោះកុង។

៦- ឯកឧត្តម **លីវ មិនច័ន្ទ** - ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋានរដ្ឋបាល, នាយកដ្ឋានសវនកម្មផ្ទៃក្នុង, ជួយចង្កោមការងារ **ឯកឧត្តម ចម បូរិទ្ធ** ពាក់ព័ន្ធនឹងការងារអគ្គាធិការដ្ឋាន និង

- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តពោធិ៍សាត់។

៧- ឯកឧត្តម **ជឹម ភ័ក្ត្រា** - ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋានវិញ្ញាបនបត្រកម្ម, នាយកដ្ឋានបញ្ញត្តកម្ម, មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា, ជួយចង្កោមការងារ **ឯកឧត្តម ចាន់ បូរិន្ទ** ពាក់ព័ន្ធនឹងនាយកដ្ឋានព័ត៌មាន នាយកដ្ឋានអភិវឌ្ឍន៍ស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់ និង

- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តត្បូងឃ្មុំ។

៨- ឯកឧត្តម **ចាន់ សារ៉ែន** - ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋាននីតិកម្ម, នាយកដ្ឋានវាយតម្លៃទទួលស្គាល់, នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម និង

- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តប៉ៃលិន។

៩- ឯកឧត្តម **ចាន់ បូរិន្ទ** - ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋានព័ត៌មាន នាយកដ្ឋានអភិវឌ្ឍន៍ស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់, ជួយចង្កោមការងារ **ឯកឧត្តម ជឹម ភ័ក្ត្រា** ពាក់ព័ន្ធនឹងនាយកដ្ឋានវិញ្ញាបនបត្រកម្ម, នាយកដ្ឋានបញ្ញត្តកម្ម, មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា និង

- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តរតនគិរី។

១០- ឯកឧត្តម **ចម បូរិទ្ធ** - ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋានបុគ្គលិក, អគ្គាធិការដ្ឋាន, ជួយចង្កោមការងារ **ឯកឧត្តម លីវ មិនច័ន្ទ** ពាក់ព័ន្ធនឹងនាយកដ្ឋានសវនកម្មផ្ទៃក្នុង និង



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣២១១ ៧៧៥
អ៊ីមែល: mih.smcabinet@gmail.com

- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តកែប។

១១- ឯកឧត្តម **ហេង ណាន**
- ជួយថ្នាក់ដឹកនាំក្រសួងលើការងារនាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ, នាយកដ្ឋានីត្យានុកូលមាត្រាសាស្ត្រ និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តឧត្តរមានជ័យ។

១២- ឯកឧត្តម **ព្រហ្ម ដួលីន**
- ជួយថ្នាក់ដឹកនាំក្រសួង លើការងារនាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ និង
- ជួយសម្របសម្រួលការងារដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្តស្ទឹងត្រែង។

**ប្រការ២ ៖** ក្រៅពីបន្ទុកការងារខាងលើ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ត្រូវទទួលអនុវត្តភារកិច្ចផ្សេងទៀតតាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី។

**ប្រការ៣ ៖** ការកំណត់បែងចែកភារកិច្ចខាងលើ អាចនឹងធ្វើការកែសម្រួលឡើងវិញអាស្រ័យលើតម្រូវការចាំបាច់។

**ប្រការ៤ ៖** តារាងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួង ដូចមានចែងក្នុងប្រការ១ មានភ្ជាប់ជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ៥ ៖** អំពីរបៀបរបបការងារប្រចាំថ្ងៃរបស់ថ្នាក់ដឹកនាំក្រសួង៖

ក- រដ្ឋលេខាធិការប្រចាំការ និងរដ្ឋមន្ត្រីស្តីទី បំពេញការងារជួយរដ្ឋមន្ត្រី ស្របទៅតាមខ្លឹមសារអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី និងភារកិច្ចរបស់រដ្ឋលេខាធិការប្រចាំការ និងអនុក្រឹត្យលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់រដ្ឋមន្ត្រីស្តីទី។

ខ- ក្នុងករណីរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការដែលទទួលបន្ទុកផ្ទាល់ អវត្តមានដោយមានការចាំបាច់មិនអាចមកបំពេញការងារនៅក្រសួងបាន លើសពីរយៈពេល ២ (ពីរ)ថ្ងៃ រដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ដែលទទួលជួយក្នុងចង្កោមការងារជាមួយគ្នាត្រូវដឹកនាំ ចាត់ចែងការងារជំនួសតាមការប្រគល់សិទ្ធិ ឬការផ្តល់ព័ត៌មានជាក់លាក់។ ករណីមានតម្រូវការចាំបាច់ណាមួយ រដ្ឋមន្ត្រីអាចសម្រេចផ្សេងពីនេះ។

គ- ត្រូវបានធ្វើប្រតិភូកម្មហត្ថលេខាជូនថ្នាក់ដឹកនាំក្រសួងជារដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ក្នុងការចុះហត្ថលេខាលើឯកសារនានាជូសរដ្ឋមន្ត្រី ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ចំពោះកិច្ចការដែលមានលក្ខណៈសាមញ្ញ មានចរិតជាការងារចរន្តធម្មតានៃដំណើរការរដ្ឋបាលប្រចាំថ្ងៃ ដោយអនុលោមតាមគោលការណ៍ដឹកនាំ ឬការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី។


ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)
ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

ឃ- ចរន្តឯកសារដែលគ្រប់អង្គភាពជំនាញត្រូវលើកយោបល់ជូនរដ្ឋមន្ត្រីពិនិត្យសម្រេច និងអមដោយមតិថ្នាក់រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការទទួលបន្ទុក ត្រូវបញ្ជូនតាមលំដាប់លំដោយឋានានុក្រម និងផ្អែកតាមការប្រគល់សិទ្ធិរបស់រដ្ឋមន្ត្រី។ ក្នុងករណីចាំបាច់ ឬកិច្ចការមានលក្ខណៈជាការប្រញាប់បន្ទាន់ចំពោះមុខ ហើយចំពេលដែលមន្ត្រី ឬថ្នាក់ដឹកនាំទទួលបន្ទុកជំនាញរូបណាអវត្តមាន នោះចរន្តឯកសារដែលត្រូវលើកយោបល់ជូនរដ្ឋមន្ត្រីពិនិត្យ និងសម្រេច អាចបញ្ជូនបន្តទៅឋានានុក្រមខ្ពស់បន្ទាប់ ហើយមានការកត់សម្គាល់ច្បាស់លាស់អំពីមូលហេតុអវត្តមាននៅលើកំណត់បង្ហាញ ដោយសាមីអង្គភាពដែលជាអ្នកលើកមតិជូនថ្នាក់ដឹកនាំក្រសួង។

ង- ថ្នាក់ដឹកនាំក្រសួង និងថ្នាក់ដឹកនាំតាមអង្គភាពជំនាញ អនុវត្តរបបប្រជុំត្រួតពិនិត្យការងារ និងដាក់ចេញជាវិធានការចាត់តាំងអនុវត្តដើម្បីពង្រឹងប្រសិទ្ធភាពការងារ តាមរយៈកិច្ចប្រជុំប្រចាំអឌ្ឍមាស ឬកិច្ចប្រជុំវិសាមញ្ញតាមការចាំបាច់។ ផ្អែកលើស្មារតីប្រជុំ និងការចង្អុលណែនាំរបស់ថ្នាក់ដឹកនាំក្រសួង គ្រប់អង្គភាពក្រោមឱវាទត្រូវចាត់ចែងឱ្យមានកិច្ចប្រជុំផ្ទៃក្នុងអង្គភាពរបស់ខ្លួន ដើម្បីផ្សព្វផ្សាយ និងអនុវត្តគោលការណ៍ដឹកនាំរួមរបស់ក្រសួង សំដៅត្រួតពិនិត្យ និងជំរុញការអនុវត្តភារកិច្ចរបស់អង្គភាពខ្លួនឱ្យបានជាប់លាប់នៅក្នុងសប្តាហ៍នីមួយៗ ឆ្លើយតបទៅនឹងសំណូមពរការងារ។

**ប្រការ៦ ៖** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៧ ៖** គ្រប់ថ្នាក់ដឹកនាំក្រសួង នាយកខុទ្ទកាល័យ អគ្គនាយក អគ្គាធិការ ប្រធានមជ្ឈមណ្ឌល គ្រប់អង្គភាពក្រោមឱវាទក្រសួងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ សុក្រ ៩ កើត ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម**

***កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ***

**កន្លែងទទួល៖**

- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ៧
- ឯកសារ-កាលប្បវត្តិ



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
៤៥ មហាវិថីព្រះនរោត្តម សង្កាត់ផ្សារថ្មី ៣
ខណ្ឌដូនពេញ ភ្នំពេញ ១២២០៥ (ព្រះរាជាណាចក្រកម្ពុជា)

ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
ទូរស័ព្ទលេខ: (៨៥៥) ២៣ ២១១ ៧៧៥
អ៊ីម៉ែល: mih.smcabinet@gmail.com

## តារាងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម ដើម្បីជួយគ្រប់គ្រងក្រសួង (សម្រាប់អាណត្តិទី៦ នៃរាជរដ្ឋាភិបាល)

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធទី១ នៃសេចក្ដីសម្រេចលេខ ២០៣ MIH / ២០១៨ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៨

| ឈ្មោះអង្គភាពចំណុះនៅរដ្ឋបាលកណ្ដាល | | រដ្ឋលេខាធិការ - អនុរដ្ឋលេខាធិការទទួលបន្ទុក | | | |
|---|---|---|---|---|---|
| អង្គភាពចំណុះផ្ទាល់ថ្នាក់ដឹកនាំក្រសួង | អង្គភាពថ្នាក់នាយកដ្ឋាន | ចង្កោមទី១ (ទទួលជួយរដ្ឋមន្ត្រីដោយផ្ទាល់) | | ចង្កោមទី២ (ទទួលជួយការងារចង្កោមទី១) | |
| | | រដ្ឋលេខាធិការ | អនុរដ្ឋលេខាធិការ | រដ្ឋលេខាធិការ | អនុរដ្ឋលេខាធិការ |
| អគ្គនាយកដ្ឋានកិច្ចការទូទៅ | នាយកដ្ឋានរដ្ឋបាល | ឯ.ឧ មាន សុភា | ឯ.ឧ លីវ មិនច័ន្ទ | ឯ.ឧ អ៊ុំ សុថា | ឯ.ឧ លីវ មិនច័ន្ទ |
| | នាយកដ្ឋានបុគ្គលិក | ឯ.ឧ អ៊ុំ សុថា | ឯ.ឧ ចម បូរិទ្ធ | ឯ.ឧ គីម ទូច | ឯ.ឧ ចម បូរិទ្ធ |
| | នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ | ឯ.ឧ គីម ទូច / អ៊ុំ សុថា | ឯ.ឧ ព្រហ្ម ដូលីន | ឯ.ឧ មាន សុភា | ឯ.ឧ ព្រហ្ម ដូលីន |
| | នាយកដ្ឋាននីតិកម្ម | ឯ.ឧ អ៊ុច បូ៉ា | ឯ.ឧ ចាន់ សារ៉ែន | ឯ.ឧ ហេង សុខគង់ | ឯ.ឧ កែ គី |
| | នាយកដ្ឋានផែនការ ស្ថិតិ សហប្រតិបត្តិការ និងការងារអាស៊ាន | ឯ.ឧ ហេង សុខគង់ | ឯ.ឧ កែ គី | ឯ.ឧ ទឹង ស៊ីនី | ឯ.ឧ កែ គី |
| អគ្គនាយកដ្ឋានឧស្សាហកម្ម | នាយកដ្ឋានកិច្ចការឧស្សាហកម្ម | ឯ.ឧ មាន សុភា | ឯ.ឧ កែ គី | ឯ.ឧ ទឹង ស៊ីនី | ឯ.ឧ កែ គី |
| | នាយកដ្ឋានបច្ចេកទេស វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា | ឯ.ឧ ទឹង ស៊ីនី | ល.ជ យុន វ៉ារី | ឯ.ឧ ហេង សុខគង់ | ល.ជ យុន វ៉ារី |
| | នាយកដ្ឋានវាយតម្លៃទទួលស្គាល់ | ឯ.ឧ អ៊ុច បូ៉ា | ឯ.ឧ ចាន់ សារ៉ែន | ឯ.ឧ ភោគ សុវណ្ណរិទ្ធ | ឯ.ឧ ចាន់ សារ៉ែន |
| | នាយកដ្ឋានកម្មសិទ្ធិឧស្សាហកម្ម | ឯ.ឧ ភោគ សុវណ្ណរិទ្ធ | ឯ.ឧ ចាន់ សារ៉ែន | ឯ.ឧ អ៊ុច បូ៉ា | ឯ.ឧ ចាន់ សារ៉ែន |
| | មជ្ឈមណ្ឌលផលិតភាពជាតិ | ឯ.ឧ ភោគ សុវណ្ណរិទ្ធ | ល.ជ យុន វ៉ារី | ឯ.ឧ ហេង សុខគង់ | ល.ជ យុន វ៉ារី |
| អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម | នាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម | ឯ.ឧ គីម ទូច | ឯ.ឧ សុន សេងហួត | ឯ.ឧ ហេង សុខគង់ | ឯ.ឧ សុន សេងហួត |
| | នាយកដ្ឋានកិច្ចការសិប្បកម្ម | ឯ.ឧ គីម ទូច | ឯ.ឧ សុន សេងហួត | ឯ.ឧ ហេង សុខគង់ | ឯ.ឧ សុន សេងហួត |
| | នាយកដ្ឋានផែនការ និងជំរុញការអភិវឌ្ឍសហគ្រាសធុនតូចនិងមធ្យម | ឯ.ឧ ហេង សុខគង់ | ឯ.ឧ សុន សេងហួត | ឯ.ឧ គីម ទូច | ឯ.ឧ សុន សេងហួត |
| អគ្គនាយកដ្ឋានទឹកស្អាត | នាយកដ្ឋានសរុប និងព័ត៌មាន | ឯ.ឧ ឯក សុនចាន់ | ឯ.ឧ សយ គីរម្យ | ឯ.ឧ អ៊ុំ សុថា | ឯ.ឧ សយ គីរម្យ |
| | នាយកដ្ឋានផែនការ និងគ្រប់គ្រងទិន្នន័យ | ឯ.ឧ ឯក សុនចាន់ | ឯ.ឧ សយ គីរម្យ | ឯ.ឧ អ៊ុំ សុថា | ឯ.ឧ សយ គីរម្យ |
| | នាយកដ្ឋានគោលនយោបាយទឹកស្អាត | ឯ.ឧ ឯក សុនចាន់ | ឯ.ឧ សយ គីរម្យ | ឯ.ឧ អ៊ុំ សុថា | ឯ.ឧ សយ គីរម្យ |
| | នាយកដ្ឋានបច្ចេកទេស និងគ្រប់គ្រងគម្រោង | ឯ.ឧ ឯក សុនចាន់ | ឯ.ឧ សយ គីរម្យ | ឯ.ឧ អ៊ុំ សុថា | ឯ.ឧ សយ គីរម្យ |
| | នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត | ឯ.ឧ ឯក សុនចាន់ | ឯ.ឧ សយ គីរម្យ | ឯ.ឧ អ៊ុំ សុថា | ឯ.ឧ សយ គីរម្យ |

| | | | | | |
|---|---|---|---|---|---|
| វិទ្យាស្ថានស្តង់ដារកម្ពុជា | នាយកដ្ឋានព័ត៌មាន | ឯ.ឧ សាត សាមី | ឯ.ឧ ចាន់ បូរិន្ទ | ឯ.ឧ សាត សាមី | ឯ.ឧ ជឹម ភ័ក្រ្តា |
| | នាយកដ្ឋានអភិវឌ្ឍន៍ស្តង់ដារ បណ្តុះបណ្តាល និងពិគ្រោះយោបល់ | ឯ.ឧ សាត សាមី | ឯ.ឧ ចាន់ បូរិន្ទ | ឯ.ឧ សាត សាមី | ឯ.ឧ ជឹម ភ័ក្រ្តា |
| | នាយកដ្ឋានវិញ្ញាបនបត្រកម្ម | ឯ.ឧ សាត សាមី | ឯ.ឧ ជឹម ភ័ក្រ្តា | ឯ.ឧ សាត សាមី | ឯ.ឧ ចាន់ បូរិន្ទ |
| | នាយកដ្ឋានបញ្ញត្តកម្ម | ឯ.ឧ សាត សាមី | ឯ.ឧ ជឹម ភ័ក្រ្តា | ឯ.ឧ សាត សាមី | ឯ.ឧ ចាន់ បូរិន្ទ |
| | មជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា | ឯ.ឧ សាត សាមី | ឯ.ឧ ជឹម ភ័ក្រ្តា | ឯ.ឧ សាត សាមី | ឯ.ឧ ចាន់ បូរិន្ទ |
| មជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | នាយកដ្ឋានវិទ្យាសាស្ត្រមាត្រាសាស្ត្រ | ល.ជ ឡាយ ណារីន | ឯ.ឧ ហេង ណន | ឯ.ឧ ជួន វន | ឯ.ឧ ហេង ណន |
| | នាយកដ្ឋាននីត្យានុកូលមាត្រាសាស្ត្រ | ល.ជ ឡាយ ណារីន | ឯ.ឧ ហេង ណន | ឯ.ឧ ជួន វន | ឯ.ឧ ហេង ណន |
| | នាយកដ្ឋានមាត្រាសាស្ត្រឧស្សាហកម្ម | ឯ.ឧ ជួន វន | ឯ.ឧ លឹម គង់ | ល.ជ ឡាយ ណារីន | ឯ.ឧ លឹម គង់ |
| | នាយកដ្ឋាននីតិកម្មមាត្រាសាស្ត្រ | ឯ.ឧ ជួន វន | ឯ.ឧ លឹម គង់ | ល.ជ ឡាយ ណារីន | ឯ.ឧ លឹម គង់ |
| អគ្គាធិការដ្ឋាន | | | ឯ.ឧ ចម បូរិទ្ធ | | ឯ.ឧ លីវ មិនច័ន្ទ |
| នាយកដ្ឋានសវនកម្មផ្ទៃក្នុង | | | ឯ.ឧ លីវ មិនច័ន្ទ | | ឯ.ឧ ចម បូរិទ្ធ |
| រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ | | ឯ.ឧ ឯក សុនចាន់ | | ឯ.ឧ អ៊ុំ សុថា | |
| រដ្ឋាករទឹកស្វយ័តសៀមរាប | | ឯ.ឧ អ៊ុំ សុថា | | ឯ.ឧ ឯក សុនចាន់ | |
| ប្រព័ន្ធស្វ័យប្រវត្តិកម្ម នៃច្រកចេញចូលតែមួយ | | ឯ.ឧ មាន សុភា | | ឯ.ឧ អ៊ុំ សុថា | |

**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ទទួលដឹកនាំរួមលើគ្រប់វិស័យ និងទទួលផ្ទាល់ ៖

- ការងារចាត់តាំងមន្ត្រី, អគ្គាធិការដ្ឋាន, នាយកដ្ឋានសវនកម្មផ្ទៃក្នុង, នាយកដ្ឋានរដ្ឋបាល, នាយកដ្ឋានបុគ្គលិក, នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ
- រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ, រដ្ឋាករទឹកស្វយ័តសៀមរាប
- ប្រព័ន្ធស្វ័យប្រវត្តិកម្មនៃច្រកចេញចូលតែមួយ
- គណៈកម្មាធិការលទ្ធកម្ម

**តារាងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងឧស្សាហកម្ម និងសិប្បកម្ម**
**ដើម្បីសម្របសម្រួលដឹកនាំ ណែនាំមន្ទីរឧស្សាហកម្ម និងសិប្បកម្មរាជធានី ខេត្ត**

(សម្រាប់អាណត្តិទី៦ នៃរាជរដ្ឋាភិបាល)

ភ្ជាប់ជាឯកសារឧបសម្ព័ន្ធទី២ នៃសេចក្ដីសម្រេចលេខ ២០៣ MIH / ២០១៨ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨

| Code | Reachtheany/Khet | រាជធានី/ខេត្ត | អនុរដ្ឋលេខាធិការ | រដ្ឋលេខាធិការ | ទេសរដ្ឋមន្ត្រី/រដ្ឋមន្ត្រី |
|---|---|---|---|---|---|
| 01 | Banteay Meanchey | បន្ទាយមានជ័យ | | ឯ.ឧ ហេង សុខគង់ | |
| 02 | Battambang | បាត់ដំបង | | ឯ.ឧ អ៊ុំ សុថា | |
| 03 | Kampong Cham | កំពង់ចាម | | ឯ.ឧ សាត សាមី | |
| 04 | Kampong Chhnang | កំពង់ឆ្នាំង | | ឯ.ឧ ទឹង ស៊ីនី | |
| 05 | Kampong Speu | កំពង់ស្ពឺ | | ឯ.ឧ កោគ សុវណ្ណរិទ្ធ | |
| 06 | Kampong Thom | កំពង់ធំ | ល.ជ យុន វ៉ារី | | |
| 07 | Kampot | កំពត | | | ឯ.ឧ ចម ប្រសិទ្ធ |
| 08 | Kandal | កណ្ដាល | | ឯ.ឧ អ៊ុច ប៉ូវ៉ា | |
| 09 | Koh Kong | កោះកុង | ឯ.ឧ សុន សេងហួត | | |
| 10 | Kratie | ក្រចេះ | ឯ.ឧ កែ គី | | |
| 11 | Mondul Kiri | មណ្ឌលគិរី | ឯ.ឧ លឹម គង់ | | |
| 12 | Phnom Penh | ភ្នំពេញ | | | ឯ.ឧ ចម ប្រសិទ្ធ |
| 13 | Preah Vihear | ព្រះវិហារ | | ឯ.ឧ គឹម ទូច | |
| 14 | Prey Veng | ព្រៃវែង | ឯ.ឧ សយ ភីរម្យ | | |
| 15 | Pursat | ពោធិ៍សាត់ | ឯ.ឧ លីវ មិនច័ន្ទ | | |
| 16 | Ratanak Kiri | រតនគិរី | ឯ.ឧ ចាន់ បូរិន្ទ | | |
| 17 | Siemreap | សៀមរាប | | ឯ.ឧ ជួន វន | |
| 18 | Preah Sihanouk | ព្រះសីហនុ | | ឯ.ឧ ឯក សុនចាន់ | |
| 19 | Stung Treng | ស្ទឹងត្រែង | ឯ.ឧ ព្រហ្ម ដូលីន | | |
| 20 | Svay Rieng | ស្វាយរៀង | | ល.ជ ឡាយ ណារីន | |
| 21 | Takeo | តាកែវ | | ឯ.ឧ មាន សុភា | |
| 22 | Kep | កែប | ឯ.ឧ ចម បូរិទ្ធ | | |
| 23 | Pailin | ប៉ៃលិន | ឯ.ឧ ចាន់ សារ៉ន | | |
| 24 | Oddar Meanchey | ឧត្តរមានជ័យ | ឯ.ឧ ហេង ណន | | |
| 25 | Tbaung Khmum | ត្បូងឃ្មុំ | ឯ.ឧ ជឹម ភ័ក្ត្រា | | |